**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខៈ ១១៤៨ មស.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការចូលរួមទប់ស្កាត់ការរីករាលដាលទ្រង់ទ្រាយធំនៃជំងឺកូវីដ-១៩

អនុវត្តតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ ទាក់ទងនឹងស្ថានការណ៍ប្រែប្រួលឆាប់រហ័សនៃការរីករាលដាលជំងឺកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ក្រសួងមុខងារសាធារណៈ សូមធ្វើការណែនាំដូចខាងក្រោម៖

១. អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពនានា ក្រោមឱវាទក្រសួងមុខងារសាធារណៈ ត្រូវគ្រប់គ្រង តាមដាន និងរាយការណ៍ជាប្រចាំពីស្ថានភាពជាក់ស្តែងពាក់ព័ន្ធដល់បញ្ហាសុខភាព សុវត្ថិភាពប្រចាំថ្ងៃ របស់មន្ត្រីរាជការក្រោមឱវាទ ទាំងក្នុងម៉ោង និងក្រៅម៉ោងបំពេញការងារ។

ប្រធានអង្គភាពដែលមានមន្ត្រីក្រោមឱវាទកំពុងស្ថិតក្នុងតំបន់រាំងខ្ទប់ (Lockdown) កំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវយកចិត្តទុកដាក់រក្សាទំនាក់ទំនងព័ត៌មានជាមួយមន្ត្រីទាំងនោះឱ្យបានជាប់លាប់ជាប្រចាំ។ ក្នុងករណីមានសំណូមពរចាំបាច់ ប្រធានអង្គភាពត្រូវរិះរកវិធីជួយដោះស្រាយឱ្យបានសមស្រប ជាអាទិ៍ ស្វែងរកកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធានាថា មន្ត្រី និងគ្រួសារដែលត្រូវរាំងខ្ទប់នោះ ទទួលបានការគាំទ្រ និងការឧបត្ថម្ភតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

២. ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងមុខងារសាធារណៈត្រូវរួមសាមគ្គីគ្នាបន្តចូលរួមបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣ការពារ និង៣កុំ ដើម្បីសុខសុវត្ថិភាពខ្លួនយើង ក្រុមគ្រួសារយើង និងសង្គមជាតិយើង។

អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន និងអង្គភាពទាំងអស់ចំណុះក្រសួងមុខងារសាធារណៈ ត្រូវធានាការបំពេញសកម្មភាពការងារប្រចាំថ្ងៃរបស់ខ្លួន ដោយគោរព អនុវត្តហ្មត់ចត់តាមប្រសាសន៍ណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីរក្សានូវប្រក្រតីភាពនៃភារកិច្ចការងារ និងការទទួលខុសត្រូវរបស់ក្រសួងមុខងារសាធារណៈ។

ក្នុងស្ថានភាពដែលត្រូវអនុវត្តនូវវិធានការចាំបាច់ដើម្បីទប់ស្កាត់ បង្ការការរីករាលដាលនៃជំងឺកូវីដ-១៩ វេនប្រចាំការការងារតាមអង្គភាពនីមួយៗត្រូវបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់ ក្នុងលក្ខណៈជាក់ស្តែង បត់បែន និងរស់រវើក។

៣. អនុវត្តតាមអនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពីកាតព្វកិច្ចក្នុងការទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ប្រធានអង្គភាពនីមួយៗត្រូវរៀបចំឱ្យមន្ត្រីក្រោមឱវាទទាំងអស់ ដែលមិនទាន់បានចាក់វ៉ាក់សាំងទៅទទួលវ៉ាក់សាំងតាមការរៀបចំរបស់អនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួងមុខងារសាធារណៈ ឱ្យបានរួសរាន់។

ក្រសួងមុខងារសាធារណៈ សង្ឃឹមលើស្មារតីយោគយល់ប្រកបដោយមនសិការរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចូលរួមអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ដើម្បីរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល និងសង្គមជាតិទាំងមូល ក្រោមការដឹកនាំប្រកបដោយបញ្ញាញាណឈ្លាសវៃរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការប្រយុទ្ធឱ្យឈ្នះជំងឺកូវីដ-១៩ សំដៅបន្តរក្សាឱ្យបាននឹងមាំនូវសុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិតរៀងទៅ។

ថ្ងៃ ច័ន្ទ ១កើត ខែចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh